01145749

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / 09 / 2015
ម៉ោង (Time/Heure): 11:02
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
**E1/330**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

**សាធារណៈ**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ព្រហស្បតិ៍ ទី ១៣ ខែ សីហា ឆ្នាំ ២០១៥

## សវនាការលើភស្តុតាង - ថ្ងៃ ៣១១

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Maddalena GHEZZI**

| **កំណត់ហេតុអ្នកចូលរួម** |
| --- |
| ចំពោះមុខ ចៅក្រម យ៉ា សុខន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូ ឧត្តរា, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖កញ្ញា ជា ស៊ីវហ៊ាង, កញ្ញា Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Travis FARR, លោក Nicolas KOUMIJAN, លោក Dale LYSAK, កញ្ញា សុង ឆវ័ន្ត, លោក ស្រ៊ា រតនៈ |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| | |
|---|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោកស្រី ទី ស្រ៊ីនណា, លោក ពេជ អង្គ, លោក វ៉ែន ពៅ | |
| សាក្សី/ដើមបណ្ដឹង៖ ឡុត ស្វយ (2-TCW-889), ឈិត យឿក (2-TCW-937) | |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ | |
| ផ្សេងៗ៖ លោក លឿង សុភក្ត័, លោក ឡុង វ៉ែត, លោក ឡាយ ណារ៉ា, កញ្ញា ស្រី ណាក់, លោក គ្រី គុងហូ, លោក ឈន សុខកុមារ, កញ្ញា Clementine PLAGNOL | |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៨.៥៧ | បញ្ចប់ម៉ោង៖ ១៦.០៦ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.០៩ | បញ្ចប់ម៉ោង៖ ១០.២៨ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣០ | បញ្ចប់ម៉ោង៖ ១៣.២៨ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤២ | បញ្ចប់ម៉ោង៖ ១៤.៥៩ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ៣៥ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ ក្រឡាបញ្ជី | ០៨.៥៧ | ០៩.០០ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០០ | ០៩.០២ |
| ការតាំងសំណួរទៅសាក្សី ឡុត ស្វយ (2-TCW-889) | មេធាវីការពារក្ដី ខៀវ សំផន | ០៩.០២ | ០៩.៣៩ |
| សំណើរបស់មេធាវីការពារក្ដី នួន ជា តាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកឯកសារមួយ និងស្នើសុំឱ្យដាក់ឯកសារពាក់ព័ន្ធនឹង តាវ៉ាល់ | មេធាវីការពារក្ដី នួន ជា សហព្រះរាជអាជ្ញា អង្គជំនុំជម្រះ | ០៩.៤១<br>០៩.៤៣<br>១៣.២៨ | ០៩.៤៣<br>០៩.៤៦<br>១៣.៣០ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅសាក្សី ឈិត យឿក (2-TCW-937) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>អង្គជំនុំជម្រះ | ០៩.៤៦<br>០៩.៥៣<br>១៤.២៤<br>១៥.៤២ | ០៩.៥៣<br>១៤.២៤<br>១៥.៤២<br>១៦.០៤ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការតាំងសំណួរទៅសាក្សី ឡុត សួយ (2-TCW-889)**

មេធាវីការពារក្តី ខៀវ សំផន បានធ្វើការតាំងសំណួរបន្តទៅសាក្សី ឡុត សួយ (2-TCW-889)។

**សំណើរបស់មេធាវីការពារក្តី នួន ជា តាមវិធាន ៨៧(៤)នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកឯកសារមួយ និងស្នើសុំឱ្យដាក់ឯកសារពាក់ព័ន្ធនឹង តាវ៉ាល់**

អង្គជំនុំជម្រះបានយល់ស្របតាមសំណើរបស់មេធាវីការពារក្តីលោក នួន ជា តាមវិធាន៨៧(៤) សុំឱ្យដាក់បញ្ចូលច្បាប់ចម្លងក្រដាស់ប្រាក់ជាពណ៌ ចូលទៅក្នុងសំណុំរឿង។ អង្គជំនុំជម្រះកត់សម្គាល់ថាឯកសារនោះត្រូវបានប្រើប្រាស់ម្តងហើយនៅក្នុងសវនាការលើកមុន (១២ សីហា ២០១៥) ដោយគ្មានការជំទាស់ ហើយថាវាសមស្របទៅនឹងឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង (E/4535)។ អង្គជំនុំជម្រះរំលឹកដល់ភាគីថា បើភាគីណាមួយមានបំណងប្រើប្រាស់ឯកសារក្នុងអំឡុងពេលសវនាការដែលមិនមាននៅក្នុងសំណុំរឿង ភាគីទាំងអស់ត្រូវដាក់សំណើរជាមុនសិន។

មេធាវីការពារក្តីលោក នួន ជា ក៏បានធ្វើសំណើផងដែរទៅសហព្រះរាជអាជ្ញា ថាតើពេលណាសហព្រះ

រាជអាជ្ញាផ្តល់ឯកសារចម្លើយសារភាពរបស់គាត់រួចហើយ និងឯកសារមួយទៀតដែលនិយាយអំពីការចាប់ខ្លួន និងការឃុំរបស់គាត់នៅ ស-២១ផងដែរ។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ខ្លួនកំពុងរង់ចាំទទួលឯកសារមួយក្នុងចំណោមឯកសារជាច្រើនមុននឹងដាក់ឯកសារទាំងអស់ចូលក្នុងសំណុំរឿង។ សហព្រះរាជអាជ្ញាបន្តថា ខ្លួននឹងផ្តល់ជូនឯកសារទាំងអស់ដល់ភាគី ក្រៅផ្លូវការនៅពេលដែលពួកគេបានឯកសារចុងក្រោយ។

**ការតាំងសំណួរទៅសាក្សី ឈិត យឿក (2-TCW-937)**

អង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួនទាក់ទងនឹងអត្តសញ្ញាណរបស់សាក្សី ព្រមទាំងប្រាប់អំពីសិទ្ធិ និងករណីកិច្ចទៅសាក្សី (2-TCW-937)។ បន្ទាប់មក សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ បានធ្វើការតាំងសំណួរបន្ត។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9060 | E305/13.23.353 | 00732996-00733059; 00728706-00728752; 00732996-00733059 | Statement of LAT Suoy (DC-Cam) | P | 00733052 00733053 | 00728747 00728748 | 01123698 01123699 |
| E3/9076 | E305/13.23.368 | 00728841-00728896; 00731151-00731190 | Statement of MUN Mut alias MUN Saroeun (DC-Cam) | P | 00728870 00728871 | 00731172 | 00595492 |
| E3/9008 | E305/13.23.306 | 00728770-00728840; 00731105- | Statement of CHHIT Yoeuk (DC-Cam) | P | 00728790 00728803 00728822 | 00731118 00731127 00731128 | 01123715 01123722 01123731 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00731150; 01123704-01123742 | | | | 00731139 | |
| E3/4535 | | 00685681-00686045 | Book by Margaret SLOCOMB entitled "An Economic History of Cambodia In the Twentieth Century" | P | | 00685772 00685827 00685868 00685869 | |

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1181 | D366/7.1.497 | 00214486-00214490; 00223175-00223177; 00612289-00612292 | Base General View of Sector 5 Northwest Zone | P | 00214490 | 0023176 | 00612291 |
| E3/1783 | D375.3 | 00659257-00659262; 00498179-00498181; 00606764-00606767 | New China News Agency, Cheng Yung-Kuei's Cambodia Visit Reported, 22 December 1977 | P | 00659260 | 0049180 0049181 | 00606766 |
| E3/2254 | D108/26.273 | 00086763-00086768; 00789703-00789710; 00834849-00834856 | S-21 Prisoner List containing names of prisoners interrogated at S-21 | P | 0086766 | 00789707 | 00834853 |
| E3/7403 | D366/7.1.127 | 00794365-00794372; 00217732-00217738 | S-21 Confession of HENG Rin alias Mei | P | | | |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1593 | | 00637356-00638099; 00678476-00678740; 00638722-00639444 | Book by Ben Kiernan entitled "The Pol Pot Regime: Race, Power, and Genocide in Cambodia under the Khmer Rougue, 1975-79" | P | 00637738 00637984 | 00678616 00678710 | 00639009 00639202 00639203 |
| E3/18 | | 00103802-00103899; 00103717-00103801; 00595365-00595529 | Book by KHIEU Samphan entitled: "Cambodia's recent history and the reasons behind the decisions I made" | P | 00103878 | 001037823 | 00595492 |
| E319/19.3.18 | | 01003875-01003890; 01044791-01044810 | Written Record of Interview of [REDACTED] | SC | 01003885 | 01044804 | |
| E127/7.1.6 | | 00907522-00907530; 00923043-00923050; 00988634-00988642 | Written Record of Interview of [REDACTED] | SC | | | |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០២)
- សម្រេចអនុញ្ញាតតាមសំណើររបស់មេធាវីការពារក្ដី នួន ជា ក្នុងការដាក់បញ្ចូលឯកសារពណ៌ធម្មជាតិនៃឯកសារ E3/4535 ។ (១៣.២៨)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផនទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.០០

| ព្រឹក នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥។ (១៦.០៥) |
|---|

| **<u>កាលវេលាសវនាការបន្ត</u>** |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា ស៊ុនហ៊ង Maddalena GHEZZI